## ស្ថានភាពចាំបាច់ (necessity)

ស្ថានភាពចាំបាច់ កើតចេញពីស្ថានភាពខាងក្រៅ ដែលជាប្រភពនៃការគម្រាម នាំឲ្យមានសកម្មភាពល្មើសឆ្លើយតបណាមួយ។ ស្រដៀងគ្នានឹងការបង្ខំ (duress) ដែរ បុគ្គល នឹងមិនអាចយកភាពចាំបាច់ធ្វើជាការដោះសារ (excuse) ទេ ប្រសិនបើ ខ្លួនបានចូលរួមបង្កើត នូវស្ថានភាពណាមួយនោះ ដែលនាំឲ្យមានបញ្ហាប្រឈម (ចូលរួមក្នុងក្រុមភេរវករដោយស្ម័គ្រចិត្ត)។ ការឆ្លើយតបក្នុងករណីមានភាពចាំបាច់ ត្រូវតែមានលក្ខណៈសមាមាត្រ (proportionate) មិនលើសពីអ្វីដែលបុគ្គលចង់ការពារ។

សម្រាប់ការឆ្លើយតប សំណួរអាចនឹងត្រូវសួរថា តើច្បាប់រំពឹងនូវការឆ្លើយតបដូចម្តេច ក្នុងស្ថានភាពបង្ខំ? តើគេរំពឹងទេថា ជនល្មើស មិនខ្វល់ពីការគម្រាមដល់ជីវិតគាត់? ស្តង់ដារដែលត្រូវបានប្រើសម្រាប់វាស់វែងថា ការឆ្លើយតបសមហេតុផលឬមិន គឺមនុស្សមានហេតុផល។ នេះក្នុងខ្លឹមសារថា ប្រឈមនឹងកាលៈទេសៈនេះ មនុស្សមានស្ថានភាពដូចគ្នា ឆ្លើយតបយ៉ាងដូចម្តេច? (Antonio Cassese, the Oxford Companion to International Criminal Justice, 2009, pp. 431-433)។

<u>**ខ្លឹមសារបន្ថែម**</u>៖ ដោយសារខ្យល់ខ្លាំងទប់មិនរួច អ្នកបើកបរដឹកអ្នកដំណើរ ៩ នាក់បានបង្ខំចិត្តបើកចូលដីចំការគេ ដើម្បីគេចពីគ្រោះថ្នាក់ក្រឡាប់ឡានស្លាប់មនុស្សទាំងនោះ។